# ការធ្វើផែនការគ្រប់គ្រងគ្រោះមហន្តរាយនៅជនបទកម្ពុជា

## សាវតា

កម្ពុជាកន្លងមកមាន គ្រោះធម្មជាតិទាក់ទងនឹងធាតុអាកាសប៉ះពាល់ជាច្រើន ដូចជា ភ្លៀងធ្លាក់ខ្លាំង ទឹកជំនន់ ការរាំងស្ងួត និងព្យុះធំៗ ហើយការប្រែប្រួលអាកាសធាតុកំពុងធ្វើឲ្យបាតុភូតទាំងនេះកាន់តែខ្លាំងក្លាឡើង។ ប្រជាជនរស់នៅតំបន់ជនបទ ងាយរងគ្រោះជាងគេពីវិបត្តិទាំងនេះ ព្រោះមានសមត្ថភាពតិច ក្នុងការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ និងមហន្តរាយនានា។ ក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយភាពងាយរងគ្រោះ និងបង្កើនភាពធន់នឹងមហន្តរាយ រដ្ឋាភិបាលបានបង្កើតយន្តការជាច្រើនសម្រាប់គ្រប់គ្រងគ្រោះអាសន្ន និងជួយដល់សហគមន៍រងគ្រោះក្នុងការទប់ទល់នឹងមហន្តរាយ និងស្តារជីវភាពឡើងវិញ។

នៅឆ្នាំ១៩៩៥ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គជគម-NCDM) បានកកើតឡើង ហើយមានទំនួលខុសត្រូវរួមលើការកសាង និងសម្របសម្រួលវិធានការឆ្លើយតប និងផែនការសង្គ្រោះបន្ទាន់។ ស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយ ដូចជា គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត (គគមខ-PDMC) គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក (គគមស-DCDM) គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ (គគមឃ-CCDM) និង ក្រុមគ្រប់គ្រងគ្រោះមហន្តរាយភូមិ (កគមភ-VDMG) ទទួលបន្ទុកធ្វើផែនការគ្រប់គ្រងមហន្តរាយនៅតាមកម្រិតរៀងៗខ្លួន ដោយមានជំនួយទ្រទ្រង់ផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការមិនមែនរដ្ឋាភិបាល (NGOs) និង គជគម។ នៅកម្រិតភូមិ និងឃុំ មានផែនការសកម្មភាពពីរប្រភេទ គឺមួយសម្រាប់ការត្រៀមរៀបចំ និងឆ្លើយតបនឹងគ្រោះអាសន្ន ហើយមួយទៀតសម្រាប់ការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ។

អត្ថបទនេះ ពណ៌នាពីដំណើរការធ្វើផែនការនៅកម្រិតភូមិ និងឃុំ ដើម្បីគ្រប់គ្រងគ្រោះមហន្តរាយនៅជនបទកម្ពុជា។ អ្នកស្រាវជ្រាវប្រើប្រាស់ព័ត៌មានបានពី លទ្ធផលបឋមនៃការសិក្សាធំមួយ (Sam 2015) ដែលធ្វើឡើងដើម្បីកំណត់ពី ១) ស្ថានភាពបណ្តាគម្រោងគ្រប់គ្រងគ្រោះមហន្តរាយផ្អែកលើសហគមន៍ និងទទួលជំនួយពី NGO និង ២) មធ្យោបាយប្រសើរបំផុតដើម្បីជំរុញការត្រៀមរៀបចំ និងការធ្វើផែនការសង្គ្រោះបន្ទាន់ប្រកបដោយប្រសិទ្ធភាពនៅតាមសហគមន៍ជនបទ។ ការសិក្សានេះ ខាងវិទ្យាស្ថានជប៉ុនសម្រាប់ការស្រោចស្រព និងដោះទឹក បានចុះកិច្ចសន្យាឲ្យអនុវត្ត។



## វិធីសាស្ត្រ

ទិន្នន័យបឋមប្រមូលបានពី ការពិភាក្សាតាមក្រុមស្នូលចំនួន ៤ ដែលបានធ្វើឡើងជាមួយសមាជិក គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកស្រីស្នំ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំត្រាំសសរ ក្នុងខេត្តសៀមរាប និងសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយសង្កាត់លលកស និងឃុំកំពង់ពោធិ៍ ក្នុងខេត្តពោធិ៍សាត់។

ព័ត៌មានបន្ថែម ប្រមូលបានពីសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ ចំនួន ៧ ធ្វើឡើងជាមួយតំណាងមកពី គជគម អង្គការភ្លែនអន្តរជាតិកម្ពុជា, អង្គការ Action Aid អង្គការជីវិតថ្លៃថ្នូរ អង្គការ Dan Church Aid/Christian Aid អង្គការ Oxfam GB និងអង្គការដៃគូសម្រាប់ការអភិវឌ្ឍកម្ពុជា។

ទិន្នន័យប្រភពទី២ ប្រមូលបានពី គជគម និង NGOs ក្នុងតំបន់ ដែលបានចូលរួមក្នុងការគ្រប់គ្រងគ្រោះអាសន្ន និងផ្តោតលើការផ្តល់ការបណ្តុះបណ្តាលពីការគ្រប់គ្រងមហន្តរាយ។

## លទ្ធផលសិក្សា

### រចនាសម្ព័ន្ធ និងមុខងារនៃ គគមឃ និង កគមភ

អនុក្រឹត្យលេខ៦១ ចុះថ្ងៃទី២៩ មិថុនា ២០០៦ បានអនុញ្ញាតឲ្យបង្កើត គគមឃ ហើយសេចក្តីណែនាំ លេខ៣១៥ ចុះថ្ងៃទី២១ កក្កដា ២០១០ បាននាំឲ្យមានការបង្កើត កគមភ។ ដូចមានបង្ហាញក្នុងរូបភាព១ គគមឃ ចែកចេញជា ៣ក្រុមដែលអនុវត្តការងារក្នុងតំបន់បីចម្បងៗ ហើយ កគមភ ចែកចេញជា ៤ក្រុម។ សមាជិកក្រុម និងគណៈកម្មាធិការទាំងអស់ ជាអ្នកស្ម័គ្រចិត្ត។ ប្រសិនបើមានជំនួយទ្រទ្រង់ពី NGO ពួកគេទទួលបានថវិកាខ្លះ បូកនិងសោហ៊ុយធ្វើដំណើរ អំពីអាជ្ញាធរឃុំរៀងៗខ្លួន។

គគមឃ មានភារកិច្ចចម្បងកសាងផែនការដើម្បីកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ, ត្រៀមរៀបចំនិងចាត់វិធានការ

---

អត្ថបទនេះ រៀបចំដោយ សំ ស្រីមុំ អ្នកស្រាវជ្រាវផ្នែកបរិស្ថាន។ សូមយោងអត្ថបទនេះថា Sam Sreymom. 2015. "Disaster Management Planning in Rural Cambodia." *Cambodia Development Review* 19(3): 5-9. Phnom Penh: CDRI.

សង្គ្រោះបន្ទាន់, អនុវត្តសកម្មភាពមានចែងលំអិតក្នុងផែនការទាំងពីរ, សម្របសម្រួលការគ្រប់គ្រងហានិភ័យមានគ្រោះមហន្តរាយនៅកម្រិតស្រុកនិងភូមិ និងសកម្មភាពសង្គ្រោះបន្ទាន់, និងអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយគ្រប់គ្រងមហន្តរាយ។ កគមភ មានតួនាទីចម្បង ពង្រឹងអនុវត្តន៍យន្តការត្រៀមរៀបចំទប់ទល់គ្រោះមហន្តរាយ តាមការចែករំលែកព័ត៌មានស្ដីពីគ្រោះមហន្តរាយដល់ប្រជាជនក្នុងមូលដ្ឋាន, ផ្សព្វផ្សាយការប្រកាសអាសន្នពីការគំរាមកំហែងបម្រុងកើតមាន និងជួយជំលៀសប្រជាជន និងសត្វចិញ្ចឹមក្នុងពេលមានគ្រោះអាសន្ន។

គគមឃ ទទួលបន្ទុកធ្វើផែនការត្រៀមទប់ទល់សម្រាប់ឃុំ ហើយ កគមភ ទទួលបន្ទុកធ្វើផែនការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយក្នុងមូលដ្ឋាន។ ស្ថាប័នទាំងពីរទទួលជំនួយទ្រទ្រង់ពី នាយកដ្ឋានជំនាញរបស់ គជគម, គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក និងខេត្ត, NGOs ក្នុងស្រុក និងដៃគូអភិវឌ្ឍន៍។

អង្គការមិនមែនរដ្ឋាភិបាលដែលជួយទ្រទ្រង់នានា អនុវត្តតាមសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ មានចែងក្នុងគោលការណ៍ណែនាំផ្នែកបច្ចេកទេសសម្រាប់ការធ្វើផែនការត្រៀម និងសង្គ្រោះបន្ទាន់ (NCDM 2013b) ព្រមទាំងផ្ដល់ការបណ្ដុះបណ្ដាលមុនពេលធ្វើផែនការ ទៅដល់សមាជិក គគមឃ និង កគមភ ។ ការបណ្ដុះបណ្ដាលគ្របដណ្ដប់លើប្រធានបទដូចខាងក្រោម៖

រូបភាព១៖ រចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ




ប្រភព៖Consortium AAC/DAC/PIN/Oxfam/SCI 2014; Leng 2014; NCDM 2013a; Khna Sanday CCDM 2013; Lolok Sa CCDM 2014

- ការប្រមូលទិន្នន័យ
- ការកសាងផែនការ
- មហន្តរាយ និងការគ្រប់គ្រង ហើយនិង គោលគំនិតជាមូលដ្ឋានស្តីពីការងើបឡើងវិញ
- យន្តការ រចនាសម្ព័ន្ធ កាតព្វកិច្ច និងតួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងមូលដ្ឋាន
- ការធ្វើផែនទីបង្ហាញពីអ្នកពាក់ព័ន្ធ
- បទពិសោធន៍រៀនសូត្របានពី ការគ្រប់គ្រងគ្រោះមហន្តរាយ
- ផលប៉ះពាល់នៃគ្រោះមហន្តរាយទៅលើ ស្ត្រី កុមារ និងក្រុមងាយរងគ្រោះដទៃទៀត
- ការវិភាគលើក្រុមងាយរងគ្រោះ
- ការធ្វើផែនទីបង្ហាញគ្រោះអន្តរាយ សម្រាប់កម្រិតធ្វើផែនការ ឬខ្នាតសមស្របណាមួយ
- សេណារីយ៉ូមានហានិភ័យ និងកម្រិតហានិភ័យ
- ការត្រៀមរៀបចំសង្គ្រោះបន្ទាន់ និងការធ្វើផែនការឆ្លើយតប
- របៀបកំណត់ធនធានមូលដ្ឋាន។

ការបណ្តុះបណ្តាលពីការប្រមូលទិន្នន័យ គ្របដណ្តប់លើរបៀបប្រមូលព័ត៌មានបឋមស្តីពីបញ្ហានានា ការលំបាកផ្សេងៗដែលប្រជាជនងាយរងគ្រោះត្រូវប្រឈមមុខ និងសមត្ថភាពរបស់ពួកគេក្នុងការដោះស្រាយបញ្ហាទាំងនោះ (NCDM 2013a, c)។

## ការកសាងផែនការត្រៀមរៀបចំសង្គ្រោះបន្ទាន់ និងឆ្លើយតប

គជគម (2013b) បានចងក្រងគោលការណ៍ណែនាំផ្នែកបច្ចេកទេសស្តីពី ការធ្វើផែនការត្រៀម និងគ្រប់គ្រងគ្រោះហានិភ័យ នៅកម្រិត ខេត្ត ក្រុង ស្រុក ខណ្ឌ ប៉ុន្តែមិនមែននៅកម្រិតឃុំទេ។ ដោយសារមិនមានគោលការណ៍ណែនាំជាក់លាក់នោះ ទើបផែនការឃុំត្រូវបានកសាងឡើង តាមរបៀបដូចគ្នានឹងផែនការនៅកម្រិតស្រុក និងខណ្ឌដែរ (រូបភាព២)។

ការធ្វើផែនការដោយមានការចូលរួម ត្រូវមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេស NGOs ផ្តល់ជំនួយទ្រទ្រង់ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក និងឃុំ។ ស្របតាមគោលការណ៍ណែនាំផ្នែកបច្ចេកទេសរបស់ គជគម សមាជិកគណៈកម្មាធិការ ត្រូវចូលរួមក្នុងការបណ្តុះបណ្តាលលើប្រធានបទជាច្រើន មុនពេលអាចចាប់ផ្តើមដំណើរការធ្វើផែនការ។ ទោះយ៉ាងនេះក្តី ខ្លឹមសារនៃផែនការត្រៀមរៀបចំសង្គ្រោះបន្ទាន់ និងឆ្លើយតប (EPRP) អាចប្រែប្រួលខុសគ្នាបន្តិចបន្តួចពី ការណែនាំរបស់ គជគម អាស្រ័យលើ NGO ដែលផ្តល់ជំនួយទ្រទ្រង់។ ផែនការទាំងនោះ ផ្តោតជាសំខាន់លើ ការត្រៀមរៀបចំនិងការឆ្លើយតបរបស់ស្ថាប័ន ធនធានដែលពួកគេត្រូវការ ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

រូបភាព២៖ ការកសាងផែនការត្រៀមរៀបចំសង្គ្រោះបន្ទាន់ និងឆ្លើយតបនៅកម្រិតឃុំ




ប្រភព៖ សម្ភាសន៍ ក្នុងឆ្នាំ២០១៤; NCDM 2013c

រូបភាព៣៖ ការបង្កើតផែនការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ




សំគាល់៖ *អ្នកពាក់ព័ន្ធ រួមមាន សហគមន៍មូលដ្ឋាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ និងស្រុក និង NGOs ផ្តល់ជំនួយទ្រទ្រង់

ប្រភព៖ Consortium AAC/DAC/PIN/Oxfam/SCI 2014

## ការកសាងផែនការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ

ផែនការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ (DRRPs) មិនមាននៅក្នុងឃុំសិក្សាទាំងបីទេ។ ប៉ុន្តែ តំណាងមកពីអង្គការជីវិតថ្លៃថ្នូរ បានប្រាប់ថា ផែនការប្រភេទនេះកន្លងមកមានបង្កើតនៅក្នុងភូមិ និងឃុំគោលដៅរបស់គម្រោង ហើយនៅទីនោះគេតែងហៅថា ផែនការគ្រប់គ្រងហានិភ័យមានគ្រោះមហន្តរាយ ឬផែនការអភិវឌ្ឍន៍ឃុំ។

DRRP កើតចេញពី ដំណើរការកំណត់តម្រូវការគ្រប់គ្រងហានិភ័យមានគ្រោះមហន្តរាយ និងការកំណត់អាទិភាពគម្រោងអភិវឌ្ឍន៍នានានៅក្នុងមូលដ្ឋាន។ មុនពេលបង្កើត កគមភ សកម្មភាពទាំងនេះ មានប្រធានភូមិទទួលខុសត្រូវជាសំខាន់ ដោយមានជំនួយទ្រទ្រង់ពីក្រុមប្រឹក្សាឃុំ។ បន្ទាប់ពីកំណត់ឃើញ ហើយ ក្រុមប្រឹក្សាឃុំត្រូវពិនិត្យជ្រើសរើសបញ្ហា និងតម្រូវការជាអាទិភាព ហើយដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ និងផែនការវិនិយោគឃុំ។ តាមនេះ នៅពេលក្រោយៗមកទៀត ការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ ក៏ត្រូវបានដាក់បញ្ចូលទៅក្នុងការធ្វើផែនការឃុំ។

ដោយមានជំនួយទ្រទ្រង់ពី NGOs នោះ ក៏មានការបង្កើតដាច់ដោយឡែកពីគ្នានូវ EPRPs និង DRRPs របស់ឃុំ។ DRRPs មានភាពខុសប្លែកពី ផែនការណែនាំដោយ គជគម និងផ្តល់គំនិតដោយ NGOs ដែលជួយទ្រទ្រង់។ គជគម ណែនាំថា DRRPs គប្បីមានទម្រង់ជាតារាងរាយមុខសកម្មភាព រីឯ NGOs ដែលផ្តល់ជំនួយ ចង់បានជារបាយការណ៍មានរៀបរាប់ពី ស្ថានភាពគ្រោះមហន្តរាយ ការវាយតម្លៃហានិភ័យ ព័ត៌មានពីស្ថាប័នមូលដ្ឋានសំខាន់ៗ និងផែនការត្រៀមរៀបចំ។ DRRPs របស់ភូមិ និងឃុំត្រូវពិនិត្យឡើងវិញរៀងរាល់ ២ ទៅ ៣ឆ្នាំម្តង។

## បញ្ហាប្រឈម

បញ្ហាប្រឈមចម្បងមួយដល់ការកសាងផែនការភូមិ និងឃុំសម្រាប់ការត្រៀមរៀបចំសង្គ្រោះបន្ទាន់ ការឆ្លើយតប និងការងើបឡើងវិញ គឺចំណេះដឹងតិចនៅក្នុងមូលដ្ឋានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ដែលបណ្តាលជាសំខាន់មកពី ភាពស្មុគស្មាញនៃការវាយតម្លៃហានិភ័យ និងសកម្មភាពធ្វើផែនការ កម្រិតអប់រំទាបក្នុងចំណោមប្រជាជនមូលដ្ឋាន និងពេលវេលាមានតិចសម្រាប់ការបណ្តុះបណ្តាល ទោះបីជាកន្លងមកការបណ្តុះបណ្តាលមានផ្តល់យ៉ាងទូលំទូលាយនៅក្នុងដំណើរការអនុវត្តគម្រោងក្តី។

បញ្ហាមួយទៀតដែលប៉ះពាល់ដល់ ការកសាងផែនការគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព គឺកង្វះពេលវេលា និងទីកន្លែង។ ការធ្វើផែនការដោយមានការចូលរួម តាមធម្មតាត្រូវមានមនុស្សច្រើនចូលរួម ប៉ុន្តែតម្រូវការ និងសំពាធក្នុងការរកចិញ្ចឹមជីវិតប្រចាំថ្ងៃ ធ្វើឲ្យគណៈកម្មាធិការ និងសមាជិកក្រុម មិនអាចមានកម្លាំង និងពេលគ្រប់គ្រាន់ មកចូលរួមឲ្យបានពេញលេញនៅក្នុងគំនិតផ្តួចផ្តើមផ្សេងៗក្នុងមូលដ្ឋានទេ។ តួយ៉ាង ការប្រមូលព័ត៌មានឲ្យគ្រប់គ្រាន់ ដើម្បីវាយតម្លៃពីហានិភ័យ និងកសាងផែនការសកម្មភាពមួយឡើង ត្រូវមានការចូលរួមពីសំណាក់ប្រជាជនមូលដ្ឋាន។ ប៉ុន្តែលទ្ធភាពក្នុងការប្រមូលទិន្នន័យ គឺមានតិច ព្រោះប្រជាជនត្រូវផ្តោតការប្រឹងប្រែង ក្នុងការរកចំណូលចិញ្ចឹមជីវិត។

ប្រសិនបើគ្មានការទទួលស្គាល់ និងដោះស្រាយឧបសគ្គទាំងនេះឲ្យបានសមស្របទេ ការបង្កើតគំនិតថ្មី និងការធ្វើផែនការអាចបង្កបរាជ័យដោយខ្លួនឯង៖ សមត្ថភាពសម្រាប់ការចូលរួមសកម្ម គ្មានការរីកចម្រើន ឬដើរមិនទាន់ការបង្កើតគំនិតថ្មីខាងបច្ចេកវិទ្យា បុគ្គលនានា និងសហគមន៍ មិនដឹងពីវិធីសម្រាប់ជួយកាត់បន្ថយការគម្រាមកំហែងដោយអាកាសធាតុ និងគ្រោះមហន្តរាយ ព្រមទាំងផលប៉ះពាល់ពាក់ព័ន្ធផ្សេងៗ, ការមានអារម្មណ៍ថាខ្លួនគ្មានសិទ្ធិអំណាច ឬការគិតថាកិច្ចប្រឹងប្រែងរបស់

ខ្លួនមិនអាចផ្លាស់ប្តូរអ្វីបាន ទាំងអស់នេះនាំឲ្យមានការស្ពឹកស្រពន់ និងការទទួលយកស្ថានភាពសព្វថ្ងៃ។ ចំណុចនេះអាចមើលឃើញខ្លះដែរក្នុងកិច្ចពិភាក្សាជាមួយសមាជិក DMCC និង គគមឃ ហើយការសាកសួរពីបញ្ហាដែលពួកគេត្រូវប្រឈម បានផ្តល់នូវគំនិតតិចតួចណាស់។

ចីរភាពនៃជំនួយសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ និងការងើបឡើងវិញ ក៏មានគូសបញ្ជាក់ដែរ។ អ្នកចូលរួមពិភាក្សា និងអ្នកឆ្លើយសម្ភាសន៍ បានសង្កត់ធ្ងន់ពីការចាំបាច់ត្រូវបន្តជំនួយទ្រទ្រង់ផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។ មូលនិធិមានតិចសម្រាប់សកម្មភាពគ្រប់គ្រង និងឆ្លើយតបនឹងគ្រោះអាសន្ន ក៏ដូចជាកង្វះការចូលរួមពីសហគមន៍ ក្នុងកិច្ចប្រឹងប្រែងគ្រប់គ្រងគ្រោះមហន្តរាយ បានរារាំងដល់ការអនុវត្តផែនការឆ្លើយតបនឹងគ្រោះអាសន្ន និងកាត់បន្ថយគ្រោះមហន្តរាយនៅកម្រិតមូលដ្ឋាន។

បញ្ហាមានមូលនិធិតិចដែលរារាំងដល់ការកសាង និងអនុវត្តផែនការ មានលើកឡើងនៅក្នុងឃុំសិក្សាទាំងបី និងដោយតំណាង NGO។ ការចូលរួមសកម្មពីសំណាក់ប្រជាជនមូលដ្ឋាន សំខាន់ខ្លាំងណាស់ ក្នុងការគ្រប់គ្រងហានិភ័យមានគ្រោះមហន្តរាយ។ ប្រជាជនមូលដ្ឋានត្រូវធ្វើសហប្រតិបត្តិការជាមួយ កគមភ និង គគមឃ នៅមុនពេល ក្នុងពេល និងនៅក្រោយពេលមានគ្រោះមហន្តរាយ។ ប៉ុន្តែការពិភាក្សា និងសម្ភាសន៍ជាច្រើនបានបញ្ជាក់យ៉ាងច្បាស់ថា ប្រជាជនខ្លះមិនអើពើនឹងការដាស់តឿនឲ្យប្រុងប្រយ័ត្នពីសំណាក់ កគមភ និង គគមឃ ទេ។ ផ្ទុយទៅវិញ ពួកគេតែងចាំដល់ពេលមានគ្រោះមហន្តរាយកើតឡើង ទើបធ្វើសកម្មភាព ហើយតាមនេះ ក៏ធ្វើឲ្យថយចុះប្រសិទ្ធភាពនៃផែនការសង្គ្រោះបន្ទាន់ និងសកម្មភាពឆ្លើយតប។

## សេចក្តីសន្និដ្ឋាន និងការផ្តល់មតិ

ទោះបីមានការពិគ្រោះយោបល់ និងការបណ្តុះបណ្តាលយ៉ាងទូលំទូលាយក៏ដោយ ក៏ការចូលរួមជាក់ស្តែងរបស់ប្រជាជនមូលដ្ឋាន ក្នុងការធ្វើផែនការគ្រប់គ្រងគ្រោះមហន្តរាយ នៅមានកម្រិតទាប។ ចំណុចនេះបង្ហាញច្បាស់ពីតម្រូវការបន្ទាន់នូវ ជំនួយទ្រទ្រង់ជាបន្តពីសំណាក់ស្ថាប័នជំនាញ និង NGOs ដល់គ្រប់ដំណាក់កាលនៃការធ្វើផែនការ និងការអនុវត្ត។

ការធ្វើផែនការឃុំ មិនមែនជាការងារថ្មីទេសម្រាប់អាជ្ញាធរភូមិឃុំដែលមានបទពិសោធន៍ក្នុងការវាយតម្លៃពីតម្រូវការ និងអាទិភាពក្នុងមូលដ្ឋាន និង ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ និងផែនការវិនិយោគ។ ទោះជាយ៉ាងនេះក្តី ការត្រៀមរៀបចំសង្គ្រោះបន្ទាន់ ការឆ្លើយតប និងការងើបឡើងវិញ បានជួបឧបសគ្គដោយសារអាជ្ញាធរមូលដ្ឋានមានសមត្ថភាពតិច ក្នុងការវាយតម្លៃលើហានិភ័យស្មុគស្មាញ និងក្នុងសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ, ឧបសគ្គទាក់ទងនឹងការចូលរួមនៅមូលដ្ឋាន ក្នុងការប្រមូលទិន្នន័យ, និងការពិបាកបំផុសឲ្យសហគមន៍ចូលរួមធ្វើសហប្រតិបត្តិការក្នុងពេលមានគ្រោះមហន្តរាយ។

មតិយោបល់ខាងក្រោមនេះ អាចជួយបំបាត់ឧបសគ្គរារាំងការធ្វើផែនការគ្រប់គ្រងគ្រោះមហន្តរាយ ដែលបានកំណត់ឃើញក្នុងការសិក្សានេះ៖

- ពង្រីកការយល់ដឹង និងសមត្ថភាពរបស់សមាជិក គគមឃ និង កគមភ តាមរយៈ ការធ្វើឲ្យការវាយតម្លៃពីហានិភ័យ និងសកម្មភាពធ្វើផែនការ មានលក្ខណៈងាយស្រួលជាងមុន និងការផ្តល់ការបណ្តុះបណ្តាលជាបន្តបន្ទាប់កាន់តែច្រើនឡើង។
- លើកកម្ពស់ការចូលរួមដ៏មានន័យពីសំណាក់សហគមន៍ តាមរយៈការជំរុញឲ្យសមាជិក គគមឃ និង កគមភ ចែករំលែកព័ត៌មានស្តីពីគ្រោះមហន្តរាយ។
- ញុំាងឲ្យការធ្វើផែនការនិងការអនុវត្តមានចីរភាពល្អតាមរយៈការធានាឲ្យមានជំនួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីស្ថាប័នជំនាញ និង NGOs ។
- បណ្តុះបណ្តាលសមាជិក គគមឃ និង កគមភ ពីរបៀបសរសេរសំណើដើម្បីស្វែងរកមូលនិធិពី NGOs និងអ្នកផ្តល់ជំនួយដទៃទៀត។
- ប្រមែប្រមូលការដឹកនាំ គំនិត និងកិច្ចប្រឹងប្រែងនៅក្នុងមូលដ្ឋាន ក្នុងអំឡុងពេលទាំងមូលនៃការអនុវត្តផែនការសកម្មភាពសហគមន៍។

## ឯកសារយោង


Consortium AAC/DAC/PIN/Oxfam/SCI. 2014. “Training of Trainers on Community Based Disaster Risk Reduction.” Phnom Penh: DIPECHO IX.

Direction No. 315. 2010. Establishment of the Village Group for Disaster Management. Phnom Penh: NCDM.

Khna Sanday Commune Disaster Management Committee. 2013. Contingency Plan for Flood. Siem Reap: Plan International. (Unpublished, available at the commune office).

Leng Heng An. 2014. “Collaboration in Disaster Risk Reduction (DRR) between the National Committee for Disaster Management and Non-Government Organizations (NGOs).” Accessed 2 March 2015, www.adrc.asia/aboutus/vrdata/finalpresentation/2013B_KHM _frp.pdf.

Lolok Sa Commune Disaster Management Committee. 2014. Contingency Plan to Disasters. (Unpublished, available at the commune office).

NCDM (National Committee for Disaster Management). 2013a. Guide Book for Trainer: Disaster Risk Management for Disaster Committee at Municipality, Province, District and Khan. Phnom Penh: NCDM.

NCDM. 2013b. Technical Guidance on Disasters and Contingency Plan Development at Municipality, Province, District and Khan. Phnom Penh: NCDM.

NCDM. 2013c. Training Document on Disasters and Contingency Plan Development. Phnom Penh: NCDM.

Sam Sreymom. 2015. “Community-Based Disaster Management Plan in Cambodia.” A report to the Japanese Institute of Irrigation and Drainage. Unpublished.

Sub-decree No. 61. 2006. Establishment of Commune Committee for Disaster Management in Cambodia. Phnom Penh: Royal Government of Cambodia.